**កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព**
**នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ**

**សេចក្តីប្រកាសព័ត៌មាន**

# ការប្រារព្ធទិវាតំបន់ដីសើមពិភពលោកនៅរាជធានីភ្នំពេញ

## ថ្ងៃទី ៣១ មករា ២០០៦

ទិវាតំបន់ដីសើមពិភពលោកនឹងប្រារព្ធធ្វើនៅសួនច្បាជ្រោយចង្វា-ចតុមុខ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ វេលាម៉ោង ៨ព្រឹក នាថ្ងៃទី ២កុម្ភៈ ឆ្នាំ២០០៦។ ព្រឹត្តិការណ៍នេះបានរៀបចំដោយក្រសួងបរិស្ថានសហកាជាមួយអង្គការម្លប់បៃតង ដែលគាំទ្រដោយកម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ *(MWBP) ។

ប្រធានបទនៃទិវាតំបន់ដីសើមឆ្នាំ២០០៦នេះគឺ "**ចំពោះមុខភាពក្រីក្រ ...តំបន់ដីសើមជាទីពឹងអាស្រ័យ** "។

ជារៀងរាល់ឆ្នាំនៅថ្ងៃទី២ ខែកុម្ភៈ ទិវាតំបន់ដីសើមត្រូវបានគេរំលឹកនៅជុំវិញពិភពលោក ក្នុងគោលបំណងលើកដំកើនការអភិរក្ស និងប្រើប្រាស់តំបន់ដីសើម់ដោយចីរភាព។

មានសកម្មភាពសំខាន់ៗបួនសំរាប់ប្រារព្ធទិវានៅឆ្នាំនេះ

១. សេចក្តីថ្លែងសុន្ទរកថាពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងពាក់ពន្ធ័ និងភ្នាក់ងារម្ចាស់ជំនួយ។

២. ការសំដែងឆាកកំប្លែងស្តីពីកាគ្រប់គ្រងតំបន់ដីសើមកម្ពុជា។

៣. ការតាំងពិពណ៌ពីសកម្មភាពតំបន់ដីសើមរបស់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ

៤. ការដង្ហែរក្បួនទូកសហគមន៏នេសាទ ។

ទិវាតំបន់ដីសើមពិភពលោកចូលរួមដោយសហគមន៏មូលដ្ឋាន និស្សិតសកលវិទ្យាល័យនានា ក្រុមហ៊ុនអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងមន្រ្តីរដ្ឋាភិបាលចូលរួមធ្វើសកម្មភាពដើម្បីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពតំបន់ដីសើមនៅកម្ពុជា ក្នុងន័យគាំទ្រជីវភាពអ្នកស្រុក និងសេដ្ឋកិច្ចជាតិ ដែលផ្តល់វិភាគទានទៅលើគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលលើការ **កាត់បន្ថយភាពក្រីក្រ**។

យោងតាមសេចក្តីថ្លែងការរបស់សម្តេចនាយករដ្ឋមន្រ្តីបានថ្លែងថា **ទីណាមានទឹក ទីនោះមានត្រី** ដូច្នេះសារៈសំខាន់នៃទឹក និងតំបន់ដីសើម បានផ្តល់នូវការចូលរួមវិភាគទានយ៉ាងសំខាន់របស់វាចំពោះការផ្តល់នូវប្រូតេអ៊ីនសំរាប់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

ឯកឧត្តមអគ្គនាយកបច្ចេកទេសនៃក្រសួងបរិស្ថានក៏បានមានប្រសាសផងដែរថា ការប្រារព្ធទិវាតំបន់ដីសើមអាចលើកឡើងនូវការយល់ដឹងជាសាធារណៈពីតំលៃ និងផលប្រយោជន៏តំបន់ដីសើម។

ប្រទេសកម្ពុជាមានតំបន់ដីសើមច្រើនជាង៣០% ហើយក្នុងនោះច្រើនជាង២០%រឺ ៣៦៥០០គម$^{២}$ អាចចាត់ជាតំបន់ដែលមានសារសំខាន់ជាអន្តរជាតិ ដូច្នេះវាតំនាងអោយ៥% នៃតំបន់ទាំងអស់ដែលមានសារសំខាន់ជាអន្តរជាតិនៅអាស៊ី។ តំបន់ដីសើមទាំងនេះស្ថិតនៅតាមដងទន្លេមេគង្គ និងវាលទំនាបនៃបឹងទន្លេ សាប និងទំនាបលិចទឹកនៅតាមបណ្តោយតំបន់ឆ្នេរសមុទ្រ។ នៅពេលចូលជាអនុសញ្ញារ៉ាមសារ តំបន់រ៉ាមសារចំនួនបីត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជាគឺ តំបន់រ៉ាមសារស្ទឹងត្រែង បឹងទន្លេឆ្មារនៃបឹងទន្លេសាប និងកោះកាពិនៅខេត្តកោះកុង។ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការយ៉ាងសកម្មឆ្ពោះទៅរកការប្រើប្រាស់អោយកាន់តែមានប្រសិទ្ធិភាពនូវការប្រើប្រាស់តំបន់ដីសើមដោយនិរន្តរភាព។ នៅក្នុងឆ្នាំ២០០១រដ្ឋាភិបាលបានប្រគល់ ឡូនេសាទចំនួន ៥៦% ដល់សហគមន៏សំរាប់ការគ្រប់គ្រងជាសហគមន៏នេសាទដើម្បីកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៏ដោយនិរន្តរភាព ។

តំបន់រ៉ាមសារស្ទឹងត្រែងជាតំបន់អនុវត្តបង្ហាញនៅកម្ពុជាសំរាប់កម្មវិធីអភិរក្សនិងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ តំបន់ដីសើមប្លែកៗដូចជា ទន្លេ បឹង ស្ទឹង និងវាលស្រែ ត្រីជាប្រភពដ៏សំខាន់ដល់ជីវភាពអ្នកស្រុក ។ នៅមូលដ្ឋាន កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គនឹងបង្ហាញពីផែនការគ្រប់គ្រងតាមរយការរួមបញ្ចូលកាអភិវឌ្ឍន៍សហគមន៍ កាអភិរក្សជីវៈចម្រុះ កសិកម្ម និងផ្នែកដទៃទៀតដោយផ្តោតលើជំរើសជីវភាពដូចជា ការផ្តល់ឥណទាន និងបង្កើនកាឡានុវត្តភាព ។

នៅក្នុងឱកាសប្រារព្ធទិវានេះ យើងខ្ញុំសូមអញ្ជើញភ្នាក់ងារសារពត៌មានដើម្បីចូលរួម និងប្រើប្រាស់ឱកាសនេះ ដើម្បីទំនាក់ទំនងជាមួយអ្នកចូលរួម និងទស្សនាការតាំងពិពណ៌ ។

ទិវាតំបន់ដីសើមពិភពលោកនិងប្រារព្ធធ្វើផងដែរនៅ ឃុំកោះស្នែង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង នៅថ្ងៃទី ០៦ ខែកុម្ភៈ ២០០៦ ។ ក្នុងទិវានេះនឹងមានអ្នកចូលរួមប្រមាណមួយពាន់នាក់ ដែលមកពីសហគមន៍មូលដ្ឋាន សិស្សសាលាបឋមសិក្សា អង្គការជាតិ និងអន្តរជាតិ ព្រមទាំងមន្ទីរពាក់ពន្ធ័ក្នុងខេត្តស្ទឹងត្រែង ។


*សំរាប់ពត៌មានលំអិតបន្ថែមសូមទំនាក់ទំនង*

**លោក សុខ វង់**

ប្រធានសំរបសំរួលកម្មវិធីជាតិ

ការិយាល័យស្ថិតនៅជាន់ទីមួយនៃក្រសួងបរិស្ថាន

ទូរសព្ទ: (០២៣) ២២២ ៣១១/១២ ទូរសារ (០២៣) ២១១ ៩៤៤

ទូរសព្ទដៃ: ០១២ ៨៥២ ៩០៤

Email: sokvong.mwbp@online.com.kh

Website: www.mekongwetlands.org


### * កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ

កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ជាកម្មវិធីរួមនៃប្រទេសទាំងបួនក្នុងអាងទន្លេមេគង្គក្រោមគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម ដែលគ្រប់គ្រងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អង្គការសហភាពអភិរក្សពិភពលោក (IUCN) និងគណៈកម្មការទន្លេមេគង្គ (MRC) ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗ ។ ដោយបានទទួលការឧបត្ថម្ភពីមូលនិធិបរិស្ថានពិភពលោក (GEF) UNDP រាជរដ្ឋាភិបាលប្រទេសហូឡង់ MRC កិច្ចផ្តួចផ្តើមទឹក និងធម្មជាតិ (WANI) និងម្ចាស់ជំនួយផ្សេងទៀត កម្មវិធីនេះព្យាយាមដោះស្រាយបញ្ហាដែលមានសារៈសំខាន់បំផុតសម្រាប់ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវធនធានធម្មជាតិក្នុងតំបន់ដីសើមនៃអាងទន្លេមេគង្គ ។

MWBP មានគោលបំណងពង្រឹងសមត្ថភាព អង្គការ និងប្រជាពលរដ្ឋដើម្បីអភិវឌ្ឍជីវភាពប្រកបដោយនិរន្តរភាព និងគ្រប់គ្រងធនធានជីវចម្រុះនៃតំបន់ដីសើមអោយបានត្រឹមត្រូវ ។ កម្មវិធីនេះធ្វើអន្តរាគមន៍រយៈពេលប្រាំឆ្នាំ (២០០៤-២០០៩) ដែលអនុវត្តនៅបីកំរិតគឺថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយមានតំបន់អនុវត្តបង្ហាញនៅតំបន់ដីសើមនៃប្រទេសនីមួយៗពោលគឺ នៅអាងទន្លេសង់ក្រោមក្រោមនៃប្រទេសថៃ ខេត្តអាត់ថាពឺនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា និងវាលទំនាបត្រែង (Plain of Reeds) នៅតំបន់ដីសណ្តូទន្លេមេគង្គនៃប្រទេសវៀតណាម ។

គោលបំណងនៃកម្មវិធីគឺដើម្បី:

១. ធ្វើអោយប្រសើរឡើងនូវការសំរបសំរួលផែនការ សំរាប់តំបន់ដីសើមពីថ្នាក់តំបន់ដល់ថ្នាក់មូលដ្ឋាន ។

២. ពង្រឹងនយោបាយ និងសេដ្ឋកិច្ចបរិស្ថានសំរាប់អភិរក្សតំបន់ដីសើម ។

៣. បង្កើត ឬ ធ្វើអោយមាន និងបែងចែកពត៌មាន ។

៤. បង្កើតជំរើសផ្សេងទៀតសំរាប់ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងធ្វើអោយប្រសើរឡើងនូវជីវភាព រស់នៅ ។

កម្មវិធីនេះ គឺជាដៃគូរវាងរាជរដ្ឋាភិបាល ម្ចាស់ជំនួយផ្សេងៗ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ផ្តល់នូវគម្រោងសំរាប់ជួយធ្វើឱ្យបរិបូរណ៍នូវកិច្ចការងារសំរាប់អភិរក្សតំបន់ដីសើម និងជីវភាពរស់នៅប្រកបដោយនិរន្តរភាពនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម ។